

សុខភាព និងជីវិត
កាន់តែប្រសើរ

# ការពារធនធានសំខាន់បំផុតរបស់អ្នក

## ជាមួយនឹងអត្ថប្រយោជន៍ជាក្រុមដ៏ពិសេស និងពេញលេញ

# AIA COMCARE

ក្នុងនាមជានិយោជកដែលយកចិត្តទុកដាក់លើនិយោជិត អ្នកត្រូវការដំណោះស្រាយដ៏សាមញ្ញ និងមានតម្លៃសមរម្យ ដើម្បីធានាលើសុខុមាលភាពរបស់ពួកគាត់។ AIA ComCare នឹងជួយអ្នកបង្ហាញការយកចិត្តទុកដាក់ ក៏ដូចជាជួយរក្សានិយោជិតរបស់អ្នកតាមរយៈអត្ថប្រយោជន៍ដ៏ល្អជាច្រើន។

AIA ComCare បានរួមបញ្ចូលការការពារលើជីវិតគ្រោះថ្នាក់ និងថ្លៃចំណាយសម្រាកមន្ទីរពេទ្យ ក្នុងដំណោះស្រាយតែមួយដែលមានភាពបត់បែន ហើយប្លែកពីដំណោះស្រាយធានារ៉ាប់រងដទៃទៀត ដើម្បីបំពេញបន្ថែមលើគម្រោងដែលអ្នកកំពុងប្រើប្រាស់។ ដំណោះស្រាយនេះនឹងជួយបង្កើនប្រសិទ្ធភាពការងាររបស់ក្រុមហ៊ុនផងដែរ។

ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត

# AIA COMCARE

## AIA ComCare ផ្តល់ជូនជាពិសេសនូវការការពារបន្ថែមសម្រាប់និយោជិតរបស់អ្នក៖

## I. ការពារសុខុមាលភាពហិរញ្ញវត្ថុរបស់ពួកគេ

ផ្តល់ជូននូវសុវត្ថិភាពហិរញ្ញវត្ថុ និងអត្ថប្រយោជន៍ការពារជាច្រើនដល់និយោជិតរបស់អ្នក រួមបញ្ចូលសេវាកម្មពីរដែលនឹងផ្តល់ជូនជាពិសេសសម្រាប់ AIA ComCare៖

### ការការពារលើជំងឺធ្ងន់ធ្ងរ

និយោជិតរបស់អ្នកនឹងទទួលបានការការពារហិរញ្ញវត្ថុនៅពេលដែលពួកគេបានធ្វើរោគវិនិច្ឆ័យឃើញថាមានជំងឺធ្ងន់ធ្ងរដូចជាមហារីក និងជំងឺដាច់សរសៃឈាមខួរក្បាល។ ការការពារនេះជួយពួកគាត់ឲ្យមានភាពស្ងប់ចិត្ត និងអាចផ្តោតសំខាន់ទៅលើការព្យាបាលឲ្យឆាប់ជាសះស្បើយ ដោយមិនព្រួយបារម្ភអំពីការចំណាយ ព្រោះការចំណាយលើការព្យាបាលទាំងនោះត្រូវបានរ៉ាប់រង។

### ការការពារលើការសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងការវះកាត់

អត្ថប្រយោជន៍សម្រាប់ការសម្រាកក្នុងមន្ទីរពេទ្យរបស់យើងធានាថានិយោជិតរបស់អ្នក នឹងទទួលបានទឹកប្រាក់ប្រចាំថ្ងៃសម្រាប់ការសម្រាកក្នុងមន្ទីរពេទ្យ នឹងសំណងលើចំណាយការវះកាត់។ និយោជិតរបស់អ្នកនឹងរិតតែមិនមានការព្រួយបារម្ភលើចំណាយទាំងនោះឡើយ។

## II. ផ្តល់ជូនបន្ថែមសម្រាប់ពួកគាត់

ផ្តល់ជូនពួកគាត់នូវអត្ថប្រយោជន៍លើការថែរក្សាសុខុមាលភាពក្នុងពេលបច្ចុប្បន្ន និងអនាគតរបស់ពួកគាត់ ដោយមិនបាច់បារម្ភពីបញ្ហាលុយកាក់។

### សេវាគ្រប់គ្រង និងប្រឹក្សាការព្យាបាលផ្ទាល់ខ្លួន (PMCM)

ការព្យាបាលនិងថែទាំលំដាប់ជាន់ខ្ពស់គឺមានភាពសំខាន់ដូចស្ថិរភាពហិរញ្ញវត្ថុដែរ។ប្រសិនបើអ្នកជ្រើសរើសយកគម្រោងដែលផ្តល់ការការពារលើជំងឺធ្ងន់ធ្ងរ ជាមួយចំនួនទឹកប្រាក់ដែលបានកំណត់ សេវាគ្រប់គ្រង និងប្រឹក្សាការព្យាបាលផ្ទាល់ខ្លួន (PMCM) ធានាថានិយោជិតរបស់អ្នកនឹងទទួលបានការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលយ៉ាងត្រឹមត្រូវ និងផ្តល់ជូនពួកគេនូវការពិគ្រោះប្រឹក្សាលើផ្នែកវេជ្ជសាស្ត្រផ្ទាល់ខ្លួន ជាមួយនឹងការផ្តល់ជាជំនួយ និងការថែទាំប្រកបដោយគុណភាពខ្ពស់។ សេវាកម្មពិសេសគឺដើម្បីផ្តល់នូវការព្យាបាលដ៏ល្អនិងត្រឹមត្រូវនៅពេលមានការសង្ស័យឬធ្វើរោគវិនិច្ឆ័យឃើញថាមានជំងឺមហារីក។

### ទិវាសុខភាព និងសុខុមាលភាព*

យើងផ្តល់ជូនលើសពីការការពារជីវិត និងហិរញ្ញវត្ថុ។ ទិវាសុខភាព និងសុខុមាលភាព របស់យើងនឹងរៀបចំឡើងដើម្បីបង្កើនការយល់ដឹងអំពីសុខភាពរបស់និយោជិតតាមរយៈការអប់រំនិងជូនដំណឹងដល់ពួកគេជាមួយកម្មវិធីនិងសកម្មភាពដែលទាក់ទងនឹងសុខភាពផ្សេងៗ។ ជាលទ្ធផល និយោជិតនឹងមានសុខភាពល្អ និងមានផលិតភាពខ្ពស់។

### ដំណោះស្រាយស្ម័គ្រចិត្តបុគ្គល (IVS)

ខណៈពេលដែល AIA ComCare ត្រូវបានបង្កើតឡើងឲ្យមានលក្ខណៈទូលំទូលាយ ប៉ុន្តែពេលខ្លះនិយោជិតអាចត្រូវការការការពារដែលស្របតម្រូវការរបស់ពួកគេក្រៅពីអត្ថប្រយោជន៍ដែលនិយោជកផ្តល់ជូន។IVSមានការផ្តល់ជូនពិសេសដល់សមាជិកដែលត្រូវបានការពារក្រោមបណ្ណសន្យារ៉ាប់រងជាក្រុម នៅពេលដែលពួកគេជ្រើសរើសទទួលការការពារពីដំណោះស្រាយធានារ៉ាប់រងបុគ្គល**។

** សម្រាប់តែក្រុមហ៊ុនដែលទទួលបានសិទ្ធិចូលរួមប៉ុណ្ណោះ។*
** * ក្នុងរយៈពេល90ថ្ងៃ បន្ទាប់ពីបណ្ណសន្យារ៉ាប់រងជាក្រុមមានសុពលភាព*

# AIA COMCARE

| អត្ថប្រយោជន៍ | ទឹកប្រាក់ធានារ៉ាប់រង |
|---|---|
| **អត្ថប្រយោជន៍ការការពារគ្រួសារ**<br>ធានាថាក្រុមគ្រួសាររបស់និយោជិតរបស់អ្នកត្រូវបានការពារផ្នែកហិរញ្ញវត្ថុក្នុងករណីគាត់ទទួលមរណភាព។ | 100% នៃអត្ថប្រយោជន៍ការពារគ្រួសារ |
| **អត្ថប្រយោជន៍នៃការស្ដារនីតិសម្បទា**<br>ផ្ដល់ប្រាក់សំណងសរុប ប្រសិនបើនិយោជិតរបស់អ្នកបាត់បង់ដៃ ឬជើង ម្ខាង ឬទាំងសងខាង ឬបាត់បង់ភ្នែកម្ខាង ឬទាំងសងខាងរបស់ពួកគេ។ | |
| • **ពិការភាពទាំងស្រុង៖**<br>ប្រសិនបើនិយោជិតទទួលពិការភាពទាំងស្រុង ពោលគឺការបាត់បង់ជើង ឬដៃទាំងសងខាង ឬការបាត់បង់ភ្នែកទាំងសងខាង ឬការបាត់បង់ជើង ឬដៃម្ខាង និងភ្នែកម្ខាង គាត់នឹងទទួលបាន៖ | 100% នៃអត្ថប្រយោជន៍លើការស្ដារនីតិសម្បទា |
| • **ពិការភាពដោយផ្នែក៖**<br>ប្រសិនបើនិយោជិតទទួលពិការភាពដោយផ្នែក ពោលគឺការបាត់បង់ជើង ឬ ដៃម្ខាង ឬការបាត់បង់ភ្នែកម្ខាង គាត់នឹងទទួលបាន៖ | រហូតដល់ 50% នៃអត្ថប្រយោជន៍លើការស្ដារនីតិសម្បទា |
| **អត្ថប្រយោជន៍សម្រាប់ការព្យាបាលជំងឺ**<br>ការពារលើចំណាយផ្នែកវេជ្ជសាស្ត្រ ពី 26 ស្ថានភាព នៃជំងឺធ្ងន់ធ្ងរសំខាន់ៗ រួមមាន៖ ជំងឺមហារីក ជំងឺដាច់សរសៃឈាមខួរក្បាល ជំងឺថ្លើម ជំងឺសួត ជំងឺបេះដូង ជំងឺក្រលៀន និងជំងឺលំពែង ចាប់តាំងពីដំណាក់កាលដំបូង ដល់ដំណាក់កាលចុងក្រោយ។ | |
| •**អាការៈជំងឺ ឬការវះកាត់ក្រុមទី 1 (ដំណាក់កាលដំបូង)៖**<br>ប្រសិនបើនិយោជិតត្រូវបានធ្វើរោគវិនិច្ឆ័យឃើញថាមានអាការៈជំងឺ/ការវះកាត់ ក្រុមទី 1 (ដំណាក់កាលដំបូង) ដែលបានកំណត់នៅក្នុងបណ្ណសន្យារ៉ាប់រង គាត់នឹងទទួលបាន៖ | រហូតដល់ 25% នៃអត្ថប្រយោជន៍សម្រាប់ការព្យាបាលជំងឺ |
| •**អាការៈជំងឺ ឬការវះកាត់ក្រុមទី 2 (ដំណាក់កាលចុងក្រោយ)៖**<br>ប្រសិនបើនិយោជិតត្រូវបានធ្វើរោគវិនិច្ឆ័យឃើញថាមានអាការៈជំងឺ/ការវះកាត់ ក្រុមទី 2 (ដំណាក់កាលចុងក្រោយ) ដែលបានកំណត់នៅក្នុងបណ្ណសន្យារ៉ាប់រង គាត់នឹងទទួលបាន៖ | 100% នៃអត្ថប្រយោជន៍សម្រាប់ការព្យាបាលជំងឺ |
| **អត្ថប្រយោជន៍សម្រាប់ការសម្រាកក្នុងមន្ទីរពេទ្យ**<br>ទឹកប្រាក់ប្រចាំថ្ងៃការពារលើចំណាយដូចខាងក្រោម នៅពេលនិយោជិតរបស់អ្នកចូលសម្រាកក្នុងមន្ទីរពេទ្យ៖ | |
| • **ចំណាយលើការសម្រាកក្នុងមន្ទីរពេទ្យ**<br>ការចំណាយប្រចាំថ្ងៃនេះ នឹងត្រូវផ្ដល់ជូនសម្រាប់ការសម្រាកក្នុងមន្ទីរពេទ្យទាំងក្នុង និងក្រៅប្រទេស។<br>• **ចំណាយការវះកាត់**<br>អត្ថប្រយោជន៍នេះ រួមបញ្ចូលការចំណាយ និងការពិនិត្យរោគសញ្ញាទាំងមុន ក្នុងកំឡុងពេល និងក្រោយពេលវះកាត់ដែលបានកំណត់។<br>• **សេវាជំនួយសង្គ្រោះបន្ទាន់នៅក្រៅប្រទេស**<br>ប្រសិនបើនិយោជិតធ្វើដំណើរទៅក្រៅប្រទេស អត្ថប្រយោជន៍នេះ នឹងផ្ដល់ជូននូវសេវាកម្មខាងក្រោម៖<br>1. ការជម្លៀសទៅមន្ទីរពេទ្យសង្គ្រោះបន្ទាន់<br>2. ការដឹកសាកសពត្រលប់មកវិញ<br>3. សេវាកម្មសាកសួរតាមទូរស័ព្ទជុំវិញពិភពលោក **24** ម៉ោង តាមរយៈលេខ **+66 2 205 7725** (ភាសាអង់គ្លេស) | |
| **អត្ថប្រយោជន៍លើមរណភាព និងរបួសដោយចៃដន្យ**<br>សុវត្ថិភាពហិរញ្ញវត្ថុត្រូវបានការពារសម្រាប់និយោជិតរបស់អ្នកឬអ្នកទទួលផលរបស់គាត់ក្នុងករណីគាត់ទទួលមរណភាពឬរងរបួសធ្ងន់ធ្ងរណាមួយដោយសារគ្រោះថ្នាក់។ | |
| • **មរណភាពដោយសារគ្រោះថ្នាក់ចៃដន្យ៖**<br>ក្នុងករណីមានមរណភាពដោយសារគ្រោះថ្នាក់ចៃដន្យ អ្នកទទួលផលដែលបានកំណត់ដោយនិយោជិតរបស់អ្នកនឹងទទួលបាន៖ | 100% នៃអត្ថប្រយោជន៍លើមរណភាព និងការរងរបួសដោយគ្រោះថ្នាក់ចៃដន្យ |
| • **ពិការភាពដោយសារគ្រោះថ្នាក់ចៃដន្យ ក្រុមទី 2 ឬការរលាកកម្រិតទីបី៖**<br>ប្រសិនបើនិយោជិតទទួលពិការភាពដោយសារគ្រោះថ្នាក់ចៃដន្យ ក្រុមទី 2 ឬការរលាកកម្រិតទីបី ដែលបានកំណត់នៅក្នុងបណ្ណសន្យារ៉ាប់រង គាត់នឹងទទួលបាន៖ | 100% នៃអត្ថប្រយោជន៍លើមរណភាព និងការរងរបួសដោយគ្រោះថ្នាក់ចៃដន្យ |
| • **ពិការភាពដោយសារគ្រោះថ្នាក់ចៃដន្យ ក្រុមទី 1 ឬការរលាកកម្រិតទីពីរ៖**<br>ប្រសិនបើនិយោជិតទទួលពិការភាពដោយសារគ្រោះថ្នាក់ចៃដន្យ ក្រុមទី 1 ឬការរលាកកម្រិតទីពីរ ដែលបានកំណត់នៅក្នុងបណ្ណសន្យារ៉ាប់រង គាត់នឹងទទួលបាន៖ | រហូតដល់ 50% នៃអត្ថប្រយោជន៍លើមរណភាព និងការរងរបួសដោយគ្រោះថ្នាក់ចៃដន្យ |

## ឧទាហរណ៍

នៅពេលដែលក្រុមហ៊ុន ABC យល់ថានិយោជិតរបស់ពួកគេគឺជាធនធានដ៏មានតម្លៃរបស់ក្រុមហ៊ុន ដូច្នេះក្រុមហ៊ុនជ្រើសរើសដំណោះស្រាយធានារ៉ាប់រង AIA ComCare សម្រាប់និយោជិតទាំង 100នាក់ ដើម្បីការពារហិរញ្ញវត្ថុ និងសុខុមាលភាព ក៏ដូចជារក្សាភាពស្មោះស្ម័គ្ររបស់និយោជិត។ AIA ComCare ផ្តល់ជូននូវភាពបត់បែនក្នុងការរៀបចំកញ្ចប់ការពារស្របតាមតម្រូវការរបស់ក្រុមហ៊ុន ហើយកញ្ចប់ខាងក្រោម គឺជាអត្ថប្រយោជន៍ដែលក្រុមហ៊ុនជ្រើសរើសឲ្យនិយោជិត៖

| អត្ថប្រយោជន៍ | អ្នកគ្រប់គ្រងជាន់ខ្ពស់ | អ្នកគ្រប់គ្រងថ្នាក់កណ្តាល | បុគ្គលិកទូទៅ |
|---|---|---|---|
| 1. អត្ថប្រយោជន៍ការពារគ្រួសារ (មរណភាពពីគ្រប់មូលហេតុ) | **US$ 40,000** | **US$ 20,000** | **US$ 10,000** |
| 2. អត្ថប្រយោជន៍លើការស្លាប់និតិសម្បទា<br>(ពិការភាពដោយផ្នែក &ពិការភាពទាំងស្រុង ពីគ្រប់មូលហេតុ) | **US$ 40,000** | **US$ 20,000** | **US$ 10,000** |
| 3. អត្ថប្រយោជន៍លើមរណភាព និងរបួសដោយចៃដន្យ<br>(អត្ថប្រយោជន៍បន្ថែម លើមរណភាព ឬពិការភាព ពីគ្រោះថ្នាក់ចៃដន្យ) | **US$ 40,000** | **US$ 20,000** | **US$ 10,000** |
| 4. អត្ថប្រយោជន៍សម្រាប់ការព្យាបាលជំងឺ៖<br>(ជំងឺធ្ងន់ធ្ងរសំខាន់ៗ ចំនួន 7 ដែលមាន 26 លក្ខខណ្ឌ) | **US$ 40,000** | **US$ 20,000** | **US$ 10,000** |

## តើនិយោជិតទទួលបានអត្ថប្រយោជន៍អ្វីខ្លះ?

| ព្រឹត្តិការណ៍ | អត្ថប្រយោជន៍របស់និយោជិត |
|---|---|
| លោក តារា ជាអ្នកគ្រប់គ្រងជាន់ខ្ពស់វ័យក្មេងម្នាក់ ដែលត្រូវបានគេធ្វើរោគវិនិច្ឆ័យឃើញថាមានជំងឺមហារីកថ្លើមដំណាក់កាលដំបូង | បន្ទាប់ពីធ្វើរោគវិនិច្ឆ័យរួច លោក តារាទ ទួលបានប្រាក់ US$ 10,000 ឬស្មើនឹង 25% នៃ US$ 40,000 ដើម្បីកាត់បន្ថយការលំបាកផ្នែកហិរញ្ញវត្ថុ និងចំណាយលើការព្យាបាលជំងឺ។ គាត់ក៏មានសិទ្ធិទទួលសេវា Medix ផ្តល់ដោយ AIA ដើម្បីទទួលបានសេវាគ្រប់គ្រង និងប្រឹក្សាការព្យាបាលផ្ទាល់ខ្លួន ហើយគាត់បានប្រើសេវាកម្មនេះ ដើម្បីស្វែងរកវិធីព្យាបាលជំងឺមហារីកដែលល្អបំផុត។ ជាមួយនឹងអត្ថប្រយោជន៍ដែលទទួលបានពី AIA លោកមិនចាំបាច់ព្រួយបារម្ភអំពីចំណាយលើការព្យាបាលជំងឺទេ ហើយអាចផ្តោតអារម្មណ៍ទាំងស្រុងទៅលើការជាសះស្បើយរបស់គាត់។ |
| លោកស្រី រ័ត្ន ជាអ្នកម្តាយ ដែលចិញ្ចឹមកូនម្នាក់ឯង និងជាអ្នកគ្រប់គ្រងថ្នាក់កណ្តាលបានជួបគ្រោះថ្នាក់នៅពេលធ្វើដំណើរទៅធ្វើការ ហើយជើងទាំងពីរត្រូវបានកាត់ចោល (ពិការភាពជាអចិន្ត្រៃយ៍) | លោកស្រី រ័ត្ន ទទួលបានប្រាក់សំណងសរុបចំនួន US$ 40,000៖ US$ 20,000 ឬស្មើនឹង 100%• នៃអត្ថប្រយោជន៍សរុបលេខ 2 (ពិការភាពដោយផ្នែក &ពិការភាពទាំងស្រុង ពីគ្រប់មូលហេតុ) និង US$ 20,000 ឬស្មើនឹង 100% នៃអត្ថប្រយោជន៍សរុបលេខ 3 (អត្ថប្រយោជន៍បន្ថែម លើមរណភាព ឬពិការភាព ពីគ្រោះថ្នាក់ចៃដន្យ) ប្រាក់សរុបនេះ នឹងជួយលោកស្រី រ័ត្ន និងកូនស្រីពីបន្ទុកហិរញ្ញវត្ថុ។ |
| លោក វាសនា ជាបុគ្គលិកទូទៅ បានទទួលមរណភាពបន្ទាប់ពីជំងឺគាំងបេះដូង | ក្រុមគ្រួសាររបស់លោក វាសនា នឹងទទួលបានប្រាក់ចំនួន US$ 10,000 ឬស្មើនឹង 100% នៃអត្ថប្រយោជន៍សរុបលេខ 1 (មរណភាពពីគ្រប់មូលហេតុ) ពី AIA ដើម្បីទ្រទ្រង់ពួកគេ និងបន្ធូរបន្ថយនូវបន្ទុកហិរញ្ញវត្ថុបន្ទាប់ពីមរណភាពរបស់មេគ្រួសារតែម្នាក់របស់ពួកគេ។ |

ខ និងលក្ខខណ្ឌត្រូវបានអនុវត្ត

## ករណីមិនធានា

### 1.ករណីមិនធានាសម្រាប់អត្ថប្រយោជន៍ការពារគ្រួសារ

អត្ថប្រយោជន៍ការពារគ្រួសារមិនធានាលើមរណភាពដែលបណ្ដាលមកពី៖

(i) ការធ្វើអត្តឃាត ការធ្វើឲ្យរបួសខ្លួនឯង ទោះបីស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតី កំឡុងពេល 2 (ពីរ) ឆ្នាំចាប់ពីថ្ងៃចេញបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទដែលចូលជាធរមាន ដោយយកកាលបរិច្ឆេទចុងក្រោយគេ ឬ

(ii) ការប្រព្រឹត្ត ឬការប៉ុនប៉ងប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ ដោយអ្នក ឬដោយសមាជិកអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល ឬ

(ii) វីរុសហ៊ីវ និង/ឬជំងឺណាមួយដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ រួមទាំងជំងឺអេដស៍ និង/ឬការផ្លាស់ប្ដូរ ការវិវត្តន៍ ឬការប្រែប្រួលនៃមេរោគអេដស៍ និង/ឬជំងឺដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ រួមទាំងជំងឺអេដស៍ ឬ

(iv) ការប្រើប្រាស់គ្រឿងញៀន ឬថ្នាំសប្បាយ ការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ដូចមានចែងនៅក្នុងច្បាប់ និង ខ និងលក្ខខណ្ឌជាធរមាន។

### 2.ករណីមិនធានាសម្រាប់អត្ថប្រយោជន៍លើការស្ដារនីតិសម្បទា

អត្ថប្រយោជន៍លើការស្ដារនីតិសម្បទា នឹងមិនធានាលើពិការភាពណាដែលបង្កឡើងដោយផ្ទាល់ ឬដោយប្រយោល ទាំងស្រុង ឬដោយផ្នែក ដោយហេតុការណ៍ណាមួយដូចខាងក្រោមឡើយ៖

(i) ការប្រឈមនឹងគ្រោះថ្នាក់ដោយចេតនា ឬប៉ុនប៉ងធ្វើបាបខ្លួនឯងដោយចេតនា ឬធ្វើឲ្យរបួសខ្លួនឯងទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ ឬ

(ii) ការចូលបម្រើក្នុងជួរកងទ័ព ក្នុងកំឡុងពេលមានប្រកាស ឬគ្មានប្រកាសសង្គ្រាមក្ដី ឬក្រោមបញ្ជាប្រតិបត្តិការសង្គ្រាម ឬការស្ដារសណ្ដាប់ធ្នាប់សាធារណៈ ឬ

(iii) ការធ្វើដំណើរចូល ការចាកចេញ ការធ្វើប្រតិបត្តិការ ការផ្ដល់សេវា ឬត្រូវបានបញ្ជូនដោយយាន ឬមធ្យោបាយធ្វើដំណើរតាមផ្លូវអាកាស លើកលែងតែក្នុងករណីសមាជិកអ្នកត្រូវបានធានារ៉ាប់រងគឺជាអ្នកដំណើរធម្មតា ឬសមាជិកអ្នកបម្រើលើយន្តហោះនៃក្រុមហ៊ុនអាកាសចរណ៍ណាមួយ ដែលធ្វើការជាប្រចាំតាមកាលវិភាគនៃអ្នកធ្វើដំណើររបស់ក្រុមហ៊ុនអាកាសចរណ៍ និងតាមគន្លងផ្លូវអាកាសសម្រាប់អ្នកធ្វើដំណើរតាមផ្លូវអាកាស ឬ

(iv) ពិការភាព ដែលបណ្ដាលមកពីបញ្ហាផ្លូវកាយ ឬផ្លូវចិត្ត ដែលកើតមានមុនកាលបរិច្ឆេទសុពលភាពនៃការធានារ៉ាប់រងរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រង ហើយដែលមិនបានបង្ហាញក្នុងពាក្យស្នើសុំ ឬរបាយការណ៍សុខភាព ឬ

(v) ការប្រព្រឹត្តបទល្មើស ព្រហ្មទណ្ឌ ប្រព្រឹត្ត ឬប៉ុនប៉ងនឹងប្រព្រឹត្ត ដោយអ្នក ឬដោយសមាជិកអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល ឬ

(vi) ការប្រើប្រាស់គ្រឿងញៀន ឬថ្នាំសប្បាយ ការសេពគ្រឿងស្រវឹងហួសកម្រិត ឬបើកបរយានជំនិះក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ដូចមានចែងនៅក្នុងច្បាប់ និង បទប្បញ្ញត្តិជាធរមាន។

### 3.ករណីមិនធានាសម្រាប់អត្ថប្រយោជន៍លើមរណភាព និងការរងរបួសបង្កដោយគ្រោះថ្នាក់ចៃដន្យ

រាល់របួសស្នាម ដែលកើតឡើងដោយផ្ទាល់ ឬដោយប្រយោល របួសទាំងស្រុង ឬផ្នែកណាមួយ ពីករណីណាមួយខាងក្រោមនេះ នឹងមិនត្រូវចាត់ចូលជារបួសបង្កដោយគ្រោះថ្នាក់ចៃដន្យ៖

(i) ហិង្សាលើរូបរាងកាយ ឬឃាតកម្ម ឬ

(ii) កូដកម្ម កុបកម្ម ចលាចលសង្គម ការបះបោរ ឬសកម្មភាពភេរវជន ឬ

(iii) ការប្រព្រឹត្ត ឬការប៉ុនប៉ងប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ ដោយអ្នក ឬដោយសមាជិកអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល ឬ

(iv) ការប្រឈមនឹងគ្រោះថ្នាក់ដោយចេតនា ឬប៉ុនប៉ងធ្វើបាបខ្លួនឯងដោយចេតនា ឬធ្វើឲ្យរបួសខ្លួនឯងទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ ឬ

(v) សង្គ្រាមដែលបានប្រកាស ឬមិនបានប្រកាស ឬបដិវត្តន៍ ឬ

(vi) ការចូលបម្រើក្នុងជួរកងទ័ព ក្នុងកំឡុងពេលមានប្រកាស ឬគ្មានប្រកាសសង្គ្រាមក្ដី ឬក្រោមបញ្ជាប្រតិបត្តិការសង្គ្រាម ឬការស្ដារសណ្ដាប់ធ្នាប់សាធារណៈ ឬ

(vii) ការចូលរួមប្រតិបត្តិចុះចាប់ខ្លួនក្នុងនាមជាមន្ត្រីអនុវត្តច្បាប់ ឬ

(viii) ការរំលោភបំពាន ឬប៉ុនប៉ងរំលោភបំពានច្បាប់ ឬបដិសេធនឹងការចាប់ខ្លួន ឬ

(ix) ការចូលរួមក្នុងអំពើហិង្សា ឬការវាយតប់គ្នានៅក្នុងកន្លែងសាធារណៈ ឬ

(x) ការប្រណាំងសេះ ឬយានយន្ត ឬ

(xi) ឧបទ្ទវហេតុដែលកើតឡើងខណៈពេលដែល ឬដោយសារសមាជិកអ្នកត្រូវបានធានារ៉ាប់រងស្ថិតក្រោមឥទ្ធិពលជាតិស្រវឹង ឱសថដែលមិនបានចេញដោយវេជ្ជបញ្ជា ឬគ្រឿងញៀនខុសច្បាប់ផ្សេងៗ ឬ

(xii) រោគក្លន ការបង្ករោគដោយផ្សិត ឬបាក់តេរី (លើកលែងតែការកើតខ្ទុះដែលកើតចេញពីមុខរបួស ឬដំបៅដែលបង្កដោយគ្រោះថ្នាក់) ឬ

(xiii) ការស្រូប ឬការប្រើប្រាស់ថ្នាំពុល ផ្សែងពុល ឬឧស្ម័នមានជាតិពុល ដោយចេតនា ឬដោយធ្វេសប្រហែស ឬ

(xiv) ការធ្វើដំណើរចូល ការចាកចេញ ការធ្វើប្រតិបត្តិការ ការផ្ដល់សេវា ឬត្រូវបានបញ្ជូនដោយយាន ឬមធ្យោបាយធ្វើដំណើរតាមផ្លូវអាកាស លើកលែងតែក្នុងករណីសមាជិកអ្នកត្រូវបានធានារ៉ាប់រងគឺជាអ្នកដំណើរធម្មតា ឬសមាជិកអ្នកបម្រើលើយន្តហោះនៃក្រុមហ៊ុនអាកាសចរណ៍ណាមួយ ដែលធ្វើការជាប្រចាំតាមកាលវិភាគនៃអ្នកធ្វើដំណើររបស់ក្រុមហ៊ុនអាកាសចរណ៍ និងតាមគន្លងផ្លូវអាកាសសម្រាប់អ្នកធ្វើដំណើរតាមផ្លូវអាកាស ឬ

(xv) ពិការភាព ដែលបណ្ដាលមកពីបញ្ហាផ្លូវកាយ ឬផ្លូវចិត្តដែលកើតមានមុនកាលបរិច្ឆេទសុពលភាពនៃការធានារ៉ាប់ រងរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រង ហើយដែលមិនបានបង្ហាញក្នុងពាក្យស្នើសុំ ឬរបាយការណ៍សុខភាព។

### 4.ករណីមិនធានាសម្រាប់អត្ថប្រយោជន៍សម្រាប់ការព្យាបាលជំងឺធ្ងន់ធ្ងរ

អត្ថប្រយោជន៍សម្រាប់ការព្យាបាល មិនធានាលើ៖

(i) ជំងឺ ឬការវះកាត់ណាមួយក្រៅពីការធ្វើរោគវិនិច្ឆ័យនៃ ឬការវះកាត់សម្រាប់អាការៈជំងឺធ្ងន់ធ្ងរដូចបានកំណត់ក្នុង អត្ថប្រយោជន៍នេះ ឬ

(ii) រោគសញ្ញា ឬអាការៈរោគនៃអាការៈជំងឺធ្ងន់ធ្ងរដែលបានកំណត់ថា ជាដំណាក់កាលចុងក្រោយត្រូវបានបង្ហាញឲ្យឃើញមុន ឬក្នុងកំឡុងពេល 90(កៅសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចេញបណ្ណសន្យារ៉ាប់រង ឬចាប់ពីកាលបរិច្ឆេទចាប់ផ្ដើមនៃអត្ថប្រយោជន៍នេះ ដោយយកកាលបរិច្ឆេទចុងក្រោយគេ ឬ

(ii) រោគសញ្ញា ឬអាការៈរោគនៃអាការៈជំងឺធ្ងន់ធ្ងរដែលបានកំណត់ជាដំណាក់កាលដំបូងបានកើតឡើងមុន ឬក្នុងកំឡុងពេល 120 (មួយរយម្ភៃ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចេញបណ្ណសន្យារ៉ាប់រង ឬចាប់ពីកាលបរិច្ឆេទចាប់ផ្ដើមនៃអត្ថប្រយោជន៍នេះ ដោយយកកាលបរិច្ឆេទចុងក្រោយគេ ឬ

(iv) អាការៈជំងឺធ្ងន់ធ្ងរកើតឡើងដោយផ្ទាល់ ឬប្រយោលពីស្ថានភាពមុនពេលធានារ៉ាប់រងដូចបានកំណត់ ដែលកើតមានមុនកាលបរិច្ឆេទចេញបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទចាប់ផ្ដើមនៃអត្ថប្រយោជន៍នេះ ដោយយកកាលបរិច្ឆេទចុងក្រោយគេ ឬ

(v) តាមយោបថរបស់ក្រុមហ៊ុន អាការៈជំងឺធ្ងន់ធ្ងរកើតមានដោយផ្ទាល់ ឬដោយប្រយោលដោយសារមានផ្ទុកមេរោគអេដស៍ ឬដោយមានការឆ្លងមេរោគអេដស៍។ ក្រុមហ៊ុនសូមរក្សាសិទ្ធិដើម្បីតម្រូវឲ្យសមាជិកអ្នកត្រូវបានធានារ៉ាប់រងទៅពិនិត្យឈាមរកមេរោគអេដស៍ ដែលជាលក្ខខណ្ឌដំបូងបង្អស់ក្នុងការទទួលយកការទាមទារសំណងណាមួយ។ ករណីលើកលែង គឺនៅពេលដែលការឆ្លងមេរោគអេដស៍ កើតឡើងដោយសារការបញ្ចូលឈាម ដូចបានកំណត់ក្នុងអត្ថប្រយោជន៍នេះ។ ចំពោះគោលបំណងនៃអត្ថប្រយោជន៍នេះ
   a. និយមន័យនៃជំងឺអេដស៍ (AIDS) ត្រូវតែជានិយមន័យដែលត្រូវបានប្រើដោយអង្គការសុខភាពពិភពលោកក្នុងឆ្នាំ 1987 ឬការកែប្រែណាមួយក្រោយមកទៀត ទៅលើនិយមន័យនោះដោយអង្គការសុខភាពពិភពលោក។
   b. ការឆ្លងមេរោគនេះ ត្រូវចាត់ទុកថាបានកើតឡើងនៅពេលដែលការពិនិត្យឈាម ឬការពិនិត្យផ្សេងៗដែលពាក់ព័ន្ធ ហើយដែលតាមយោបល់របស់ក្រុមហ៊ុន បង្ហាញថាមានផ្ទុកមេរោគអេដស៍ ឬអង់ទីករប្រឆាំងមេរោគនេះ។

(iv) អាការៈជំងឺធ្ងន់ធ្ងរមានកម្រិតដូចគ្នា ឬទាបជាងអាការៈជំងឺធ្ងន់ធ្ងរដែលបានទាមទារសំណងពីមុន ឬ

(vii) រាល់ការធ្វើរោគវិនិច្ឆ័យលើអាការៈជំងឺធ្ងន់ធ្ងរណាមួយ ដែលបណ្ដាលមកពីជំងឺ ឬការឆ្លងមេរោគពីកំណើត ទោះដោយផ្ទាល់ ឬដោយប្រយោល ដែលត្រូវបានពិនិត្យឃើញ ឬធ្វើរោគវិនិច្ឆ័យមុនពេលសមាជិកអ្នកត្រូវបានធានារ៉ាប់រងមានអាយុ 17 (ដប់ប្រាំពីរ) ឆ្នាំ ឬ

(viii) រាល់អាការៈជំងឺធ្ងន់ធ្ងរដែលបណ្ដាលមកពីការធ្វើឲ្យរបួសខ្លួនឯង ឬ

(ix) រាល់អាការៈជំងឺធ្ងន់ធ្ងរ ដែលស្ថិតនៅក្រោមដំណាក់កាលដំបូងកើតឡើងដោយផ្ទាល់ពីការពិសារគ្រឿងស្រវឹង ឬប្រើប្រាស់ថ្នាំញៀនហួសហេតុ ឬ

(x) អាការៈជំងឺធ្ងន់ធ្ងរណាមួយដែលបណ្ដាលមកពីស្ថានភាពផ្លូវកាយ ឬផ្លូវចិត្តដែលបានកើតមានមុនកាលបរិច្ឆេទចេញបណ្ណសន្យារ៉ាប់រង ហើយដែលមិនបានបង្ហាញក្នុងពាក្យស្នើសុំធានារ៉ាប់រង ឬរបាយការណ៍សុខភាព ឬ

(xi) ការបរិច្ចាគផ្នែកណាមួយនៃរូបរាងកាយរបស់អ្នកដែលត្រូវបានធានារ៉ាប់រង។

## 5.ករណីមិនធានាសម្រាប់អត្ថប្រយោជន៍សម្រាប់ចំណាយលើការសម្រាកក្នុងមន្ទីរពេទ្យ

### •ករណីមិនធានាសម្រាប់ចំណាយលើការសម្រាកក្នុងមន្ទីរពេទ្យ ឬចំណាយលើការវះកាត់

អត្ថប្រយោជន៍នេះ មិនធានាចំណាយលើការសម្រាកក្នុងមន្ទីរពេទ្យ ឬចំណាយលើការវះកាត់ណាមួយដែលបង្កឡើងដោយផ្ទាល់ ឬ ដោយប្រយោល ទាំងស្រុង ឬ ដោយផ្នែក ដោយហេតុការណ៍ណាមួយខាងក្រោមឡើយ៖

(i) ចំណាយដែលបណ្ដាលមកពីស្ថានភាពមុនពេលធានារ៉ាប់រង ឬ

(ii) ចំណាយដែលបណ្ដាលមកពីការព្យាបាលមិនឲ្យមានកូន ការបង្កកំណើតសិប្បនិម្មិត ការស៊ើបអង្កេត ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលជំងឺអារ រួមទាំងវិធានការពន្យារកំណើត ការធ្វើតេស្ត ឬការប្រឹក្សាយោបល់អំពីហ្សែន ការព្យាបាលដែលកើតឡើងដោយ ឬលទ្ធផលពីការពរពោះ ការសម្រាលកូន ឬការរំលូតកូន ឬ

(iii) ចំណាយណាដែលកើតឡើងសម្រាប់ជំនួយកែតម្រូវកែវភ្នែកជំនួយការស្ដាប់ និងការព្យាបាលនៃកំហុសឆ្លុះឆ្លងលើកលែងតែមានការចាំបាច់ពីវេជ្ជបណ្ឌិតជំងឺទូទៅ ឬ

(iv) ចំណាយណាមួយដែលកើតឡើងសម្រាប់ការព្យាបាលពីការសេពគ្រឿងស្រវឹង ការសេពគ្រឿងញៀន ឬផលវិបាកណាមួយផ្សេងទៀតដែលកើតឡើងពីគ្រឿងស្រវឹង ឬគ្រឿងញៀន ការទទួលទានឱសថដែលមិនមានវេជ្ជបញ្ជា ការប្រើឱសថលើសកម្រិតដោយចៃដន្យ ឬដោយចេតនា ឬ

(v) ចំណាយណាមួយដែលកើតឡើងនៃគ្រប់ទម្រង់នៃការថែទាំទន្តសាស្ត្រ ឬការវះកាត់ណាមួយលើកលែងតែវេជ្ជបណ្ឌិតជំងឺទូទៅតម្រូវឲ្យធ្វើ និងបានបង្កឡើងពីគ្រោះថ្នាក់ចៃដន្យ (មិនរាប់បញ្ចូលការចំណាយទាក់ទងនឹងការដាំបង្គោលធ្មេញឡើយ) ឬ

(vi) ការចំណាយណាមួយកើតឡើងសម្រាប់ការវះកាត់កែសម្ផស្ស ឬការវះកាត់ដែលជ្រើសរើសបាន លើកលែងតែវេជ្ជបណ្ឌិតជំងឺទូទៅតម្រូវឲ្យធ្វើ ឬ

(vii) ចំណាយណាមួយដែលកើតឡើងសម្រាប់ការត្រួតពិនិត្យសុខភាពប្រចាំឆ្នាំ ឬថែទាំនៅមជ្ឈមណ្ឌល ការថែទាំផ្សេងៗ ឬ

(viii) ចំណាយណាមួយដែលបានកើតឡើងសម្រាប់ការព្យាបាល ឬការវះកាត់សម្រាប់ សាច់ដុះក្នុងបំពង់ក ឬសាច់ដុះក្នុងច្រមុះ រោគក្លន ជំងឺរលាកក្រពេញប្រូស្តាត ជំងឺ hydrocele ការរលាកភ្នាសរន្ធឆ្អឹង ការកាត់ស្បែក ឬជំងឺនៃប្រព័ន្ធបន្តពូជរបស់ស្ត្រី ឬ

(ix) ចំណាយណាមួយដែលទាក់ទងនឹងវីរុសហ៊ីវ និង/ឬជំងឺណាមួយដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ រួមទាំងជំងឺអេដស៍ និង/ឬការផ្លាស់ប្ដូរ ការវិវត្តន៍ ឬការប្រែប្រួលនៃមេរោគអេដស៍ និង/ឬជំងឺដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ រួមទាំងជំងឺអេដស៍ ឬ

(x) ចំណាយណាមួយដែលកើតឡើងសម្រាប់សេវាវេជ្ជសាស្ត្រ ឬការព្យាបាលក្រៅពីវេជ្ជសាស្ត្ររបស់លោកខាងលិច រួមមានការចាក់ម្ជុលវិទ្យាសាស្ត្រ ការព្យាបាល acupressure ការព្យាបាលឆ្អឹង ការព្យាបាលដោយប្រើថ្នាំផ្សំពី   រុក្ខជាតិ ការសណ្ដំ ការព្យាបាលដោយការម៉ាស្សា ការព្យាបាលដោយប្រើក្លិនក្រអូប និងទម្រង់ផ្សេងទៀតនៃការព្យាបាល ការពិសោធន៍ ការស៊ើបអង្កេត ឬសេវាកម្មដែលមិនមានការបញ្ជាក់ច្បាស់ លើកលែងតែមានការយល់ព្រមពីក្រុមហ៊ុន ឬ

(xi) ចំណាយណាមួយដែលបានកើតឡើងសម្រាប់ការឃុំឃាំងនៅក្នុងមន្ទីរពេទ្យណាមួយ ដែលជាកន្លែងសម្រាក ឬមជ្ឈមណ្ឌលថែទាំអ្នកជំងឺ ឬគ្រឹះស្ថានសម្រាប់ការស្ដារនីតិសម្បទា ឬគ្រឹះស្ថានស្រដៀងគ្នា ឬកន្លែងដែលពាក់ព័ន្ធនឹងការថែទាំពីគ្រឿងស្រវឹង ឬគ្រឿងញៀន ឬ

(xii) ចំណាយណាមួយកើតឡើងសម្រាប់ការសម្រាកក្នុងមន្ទីរពេទ្យ ដែលមិនសមហេតុផល ឬ

(xiii) ចំណាយណាមួយសម្រាប់សេវាកម្មលើការអប់រំផ្សេងៗ ដូចជាការព្យាបាលលើការនិយាយស្ដី ការធ្វើអប់រំផ្នែកជំងឺទឹកនោមផ្អែម និងសេវាអាហារូបត្ថម្ភ ឬសេវាកម្មគាំទ្រជាក្រុម ឬ

(xiv) ចំណាយណាមួយដែលបានកើតឡើង សម្រាប់បទល្មើសព្រហ្មទណ្ឌរបស់ម្ចាស់បណ្ណសន្យារ៉ាប់រងសមាជិកអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផលលើការរំលោភបំពានលើច្បាប់ និងបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា ឬប្រសិនបើបទល្មើសព្រហ្មទណ្ឌ កើតឡើងនៅក្រៅព្រះរាជាណាចក្រកម្ពុជាដោយការរំលោភបំពានលើច្បាប់ និងបទប្បញ្ញត្តិរបស់ប្រទេសនោះ ឬការគេចពីដីកាចាប់ខ្លួន ឬ

(xv) ចំណាយណាមួយដែលបានកើតឡើងសម្រាប់ការស៊ើបអង្កេត ការព្យាបាល ឬការវះកាត់ណាមួយសម្រាប់ជំងឺពីកំណើត ដែលបានផ្ដល់ជាសញ្ញា ឬរោគសញ្ញា ឬត្រូវបានធ្វើរោគវិនិច្ឆ័យមុនពេលដែលសមាជិកអ្នកត្រូវបានធានារ៉ាប់រងមានអាយុ 17 (ដប់ប្រាំពីរ) ឆ្នាំ ឬ

(xvi) ចំណាយណាមួយដែលកើតឡើងពីសេវាសុខភាព ដែលមិនមានភាពចាំបាច់ក្នុងការព្យាបាល តាមការយល់ឃើញរបស់វេជ្ជបណ្ឌិតជំងឺទូទៅ ឬ
(xvii) ចំណាយណាមួយដែលកើតឡើងចំពោះសេវាកម្ម និងការផ្គត់ផ្គង់ សម្រាប់ការបញ្ឈប់ការជក់បារី និងការព្យាបាលនៃការញៀនជាតិនីកូទីន ឬ
(xviii) ចំណាយណាមួយដែលបានកើតឡើងសម្រាប់សេវាកម្ម ដែលផ្តល់ជូនដោយវេជ្ជបណ្ឌិតជំងឺទូទៅដែលមានទីលំនៅស្របច្បាប់ដូចគ្នានឹងសមាជិកអ្នកត្រូវបានធានារ៉ាប់រង ឬដែលជាសមាជិកក្រុមគ្រួសាររបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រង រួមមាន ប្តីប្រពន្ធ បងប្អូនប្រុសស្រី ឪពុកម្តាយ ឬកូន ឬសេវាកម្មដែលផ្តល់ជូនដោយភ្នាក់ងាររបស់ក្រុមហ៊ុន ឬ
(xix) ចំណាយណាមួយដែលបានកើតឡើងសម្រាប់ការថែទាំតាមគ្លីនិក ការថែទាំប្រភេទណាមួយ ដូចជា មជ្ឈមណ្ឌលថែទាំក្មេង កន្លែងថែទាំអ្នកជំងឺដំណាក់កាលចុងក្រោយ ការថែទាំដោយគិលានុប្បដ្ឋាយិកាឯកជន ការថែទាំតាមផ្ទះ លុះត្រាតែមានការយល់ព្រមជាមុនពីវេជ្ជបណ្ឌិតជំងឺទូទៅនៃបណ្តាញរបស់ក្រុមហ៊ុន ឬ
(xx) ចំណាយណាមួយដែលបានកើតឡើងសម្រាប់សេវាកម្ម និងការផ្គត់ផ្គង់ដែលបានផ្តល់ដោយអ្នករកស៊ីរៀបចំសព ឬអ្នករកស៊ីរៀបចំបុណ្យសព រួមបញ្ចូល ប៉ុន្តែមិនកំណត់ត្រឹម ថ្លៃក្តារមឈូស ការរក្សាទុកសាកសព និង / ឬការបូជាសព ឬ
(xxi) ចំណាយណាមួយដែលបង្កឡើងពីមូលហេតុផ្សេងៗ ក្រៅពីការរងរបួសបង្កដោយគ្រោះថ្នាក់ចៃដន្យ ប្រសិនបើមិនបានជ្រើសរើសជម្រើសពេញលេញនៅលើវិញ្ញាបនបត្រធានារ៉ាប់រង និងបញ្ជីសមាជិក ឬ
(xxii) ចំណាយណាមួយដែលដូចនឹងករណីមិនធានាណាមួយនៅក្នុងបណ្ណសន្យារ៉ាប់រងនេះ។

**•ករណីមិនធានាសម្រាប់សេវាជំនួយសង្គ្រោះបន្ទាន់នៅក្រៅប្រទេស**

ការព្យាបាល លក្ខខណ្ឌ ឬសកម្មភាព និងចំណាយផ្សេងៗ ដែលពាក់ព័ន្ធ និងបណ្តាលពីចំណុចទាំងនេះ នឹងមិនត្រូវបានធានានោះទេ៖

(i) ចំណាយណាមួយដែលកើតពីស្ថានភាពមុនពេលធានារ៉ាប់រង ឬ
(ii) ករណីធ្វើការជម្លៀសទៅមន្ទីរពេទ្យសង្គ្រោះបន្ទាន់ សម្រាប់លក្ខខណ្ឌសុខភាពតែមួយរបស់សមាជិកអ្នកត្រូវបានធានារ៉ាប់រងក្នុងរយៈពេលមួយឆ្នាំនៃរយៈពេលធានារបស់បណ្ណសន្យារ៉ាប់រង ឬ
(iii) ចំណាយណាមួយដែលមិនត្រូវបានធានាដោយអត្ថប្រយោជន៍នេះ ហើយមិនត្រូវបានអនុម័តដោយអ្នកផ្តល់សេវាជាមុនជាលាយលក្ខណ៍អក្សរ ឬមិនបានរៀបចំដោយអ្នកផ្តល់សេវា។ ករណីមិនធានានេះ នឹងមិនត្រូវអនុវត្តលើការជម្លៀសទៅកាន់មន្ទីរពេទ្យសង្គ្រោះបន្ទាន់ពីតំបន់ដាច់ស្រយាល នៅពេលដែលមិនអាចទាក់ទងអ្នកផ្តល់សេវាបានជាមុន ហើយការយឺតយ៉ាវអាចបង្កឲ្យសមាជិកអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព ឬរងគ្រោះថ្នាក់ ឬ
(iv) ករណីណាដែលកើតឡើងនៅពេលដែលសមាជិកអ្នកត្រូវបានធានារ៉ាប់រង ឋិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ
(v) ចំណាយណាមួយដែលកើតមានសម្រាប់សមាជិកអ្នកត្រូវបានធានារ៉ាប់រង ដែលធ្វើដំណើរទៅក្រៅព្រះរាជាណាចក្រកម្ពុជាមិនស្របតាមដំបូន្មានរបស់វេជ្ជបណ្ឌិតជំនាញឯកទេស ឬក្នុងគោលបំណងទទួលការព្យាបាលវេជ្ជសាស្ត្រ ឬសម្រាកដើម្បីជាសះស្បើយក្រោយពីបានទទួលគ្រោះថ្នាក់ ជំងឺ ឬស្ថានភាពមុនពេលធានារ៉ាប់រង ឬ
(vi) ការចំណាយណាមួយសម្រាប់ការជម្លៀសទៅមន្ទីពេទ្យសង្គ្រោះបន្ទាន់ ប្រសិនបើសមាជិកអ្នកត្រូវបានធានារ៉ាប់រងមិនមានលក្ខខណ្ឌវេជ្ជសាស្ត្រធ្ងន់ធ្ងរ និង/ឬវេជ្ជបណ្ឌិតជំនាញឯកទេសរបស់អ្នកផ្តល់ សេវាគិតថាសមាជិកអ្នកត្រូវបានធានារ៉ាប់រងអាចទទួលបានការព្យាបាលក្នុងប្រទេសកើតហេតុ ឬអាចរងចាំទទួលការព្យាបាលនៅពេលត្រលប់មកព្រះរាជាណាចក្រកម្ពុជាវិញ ឬ
(vii) ចំណាយណាមួយសម្រាប់ការជម្លៀសទៅមន្ទីរពេទ្យសង្គ្រោះបន្ទាន់ ដែលវេជ្ជបណ្ឌិតជំនាញឯកទេសរបស់អ្នកផ្តល់សេវាគិតថាសមាជិកអ្នកត្រូវបានធានារ៉ាប់រងអាចធ្វើដំណើរជាលក្ខណៈអ្នកធ្វើដំណើរធម្មតា ដោយមិនត្រូវការសេវាវេជ្ជសាស្ត្រភ្ជាប់ជាមួយ ឬ
(viii) ការព្យាបាល ឬចំណាយណាមួយពាក់ព័ន្ធនឹងការសម្រាលកូន ការរលូតកូន ឬការមានផ្ទៃពោះ។ ការលើកលែងនេះនឹងមិនអនុវត្តលើការមានផ្ទៃពោះខុសប្រក្រតី ឬផលវិបាកស្ថានភាពផ្ទៃពោះធ្ងន់ធ្ងរដែលបង្កគ្រោះថ្នាក់ដល់ម្តាយ និង/ឬកូនដែលមិនទាន់កើតក្នុងរយៈពេល 24 សប្តាហ៍ដំបូងនៃការមានផ្ទៃពោះ ឬ
(ix) ចំណាយណាមួយដែលពាក់ព័ន្ធនឹងគ្រោះថ្នាក់ ឬរបួសដែលកើតឡើងខណៈដែលសមាជិកអ្នកត្រូវបានធានារ៉ាប់រងបានចូលរួមសកម្មភាពដូចជា ចូលមើលជ្រលងភ្នំ ឡើងភ្នំ ឡើងលើភ្នំតាមជញ្ជាំងថ្មភ្នំ ដែលទាមទារឲ្យប្រើគន្លងផ្លូវច្បាស់លាស់ ឬខ្សែពួរ មើលជ្រលងភ្នំ ហោះលោតពីទីអាកាសខ្ពស់ លោតឆាត់យោង លោតពីទីខ្ពស់ដោយប្រើខ្សែពួរ ជិះបាឡុង ជិះឧបករណ៍សំកាំងលើអាកាស ការជ្រមុជជ្រៅក្នុងសមុទ្រដោយប្រើម្ជូកការពារ និងភ្ជាប់ទុយោដកដង្ហើម ការហ្វឹកហាត់ក្បាច់គុណ ការប្រកួតប្រជែង ប្រណាំងផ្សេងដែលក្រៅពីការប្រណាំងដោយប្រើជើង ឬសកម្មភាពកីឡាផ្សេងដែលជាលក្ខខណៈអាជីព ឬមានការឧបត្ថម្ភ ឬ
(x) ចំណាយណាមួយដែលកើតឡើងសម្រាប់ជំងឺផ្នែកសតិអារម្មណ៍ ផ្លូវចិត្ត និងផ្នែកប្រសាទ ឬ
(xi) ចំណាយណាមួយដែលកើតឡើងដោយលទ្ធផលនៃការបង្ករបួសខ្លួនឯង អត្តឃាត ការប្រើប្រាស់ថ្នាំញៀន ការប្រើប្រាស់គ្រឿងស្រវឹង ឬជំងឺកាមរោគ ឬ
(xii) ចំណាយណាមួយដែលកើតឡើងដោយជំងឺអេដស៍ ឬលក្ខខណ្ឌដែលពាក់ព័ន្ធនឹងជំងឺនេះ ឬ
(xiii) ចំណាយណាមួយដែលទាក់ទងនឹងសមាជិកអ្នកត្រូវបានធានារ៉ាប់រងធ្វើការធ្វើដំណើរផ្លូវអាកាសតាមទម្រង់ផ្សេងៗ លើកលែងតែជាអ្នកធ្វើដំណើរតាមអាកាសដែលមានជើងហោះហើរត្រឹមត្រូវ ឬតាមយន្តហោះដែលធ្វើដំណើរតាមផ្លូវអាកាសមានចុះបញ្ជីការត្រឹមត្រូវ ឬ
(xiv) ចំណាយណាមួយដែលសមាជិកអ្នកត្រូវបានធានារ៉ាប់រងពាក់ព័ន្ធនឹងការប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តបទល្មើស ឬ
(xv) ការចំណាយណាមួយដែលពាក់ព័ន្ធនឹងការព្យាបាលដែលធ្វើដោយ ឬបញ្ជាដោយវេជ្ជបណ្ឌិតជំងឺទូទៅដែលមិនបានចុះបញ្ជីការទៅតាមបទដ្ឋានការអនុវត្តវេជ្ជសាស្ត្រ ក្នុងប្រទេសដែលធ្វើការព្យាបាល ឬ
(xvi) ចំណាយណាមួយដែលកើតឡើងដោយសារតែសមាជិកអ្នកត្រូវបានធានារ៉ាប់រងបានចូលរួមបំពេញសេវាកងទ័ព ឬនគរបាលនៃប្រទេសណាមួយ ការ
(xvi) ចូលរួមសង្គ្រាមយ៉ាងសកម្ម (ប្រកាស ឬមិនប្រកាសក្តី) ការឈ្លានពាន សកម្មភាពសត្រូវនឹងជនបរទេស ភាពជាសត្រូវ សង្គ្រាមស៊ីវិល ការបះបោរ កុបកម្ម បដិវត្តន៍ ឬចលាចល ឬ
(xvii) ចំណាយណាមួយដែលកើតពីប្រតិកម្ម ឬចំហាយសាយភាពជាតិវិទ្យុសកម្ម ឬ
(xviiii) ចំណាយណាមួយដែលកើតឡើងសម្រាប់ ឬមកពីលទ្ធផលនៃសកម្មភាពដែលតម្រូវលើនាវា ឬវេទិការោងចក្រប្រេង ឬនៅទីតាំងច្រាំងស្រដៀងគ្នា ឬ
(xix) ចំណាយណាមួយដែលសមាជិកអ្នកត្រូវបានធានារ៉ាប់រងមានអាយុច្រើនជាង 70 ឆ្នាំ ឬ
(xx) ចំណាយណាមួយដែលពាក់ព័ន្ធនឹងការប្រើប្រាស់ ឬបញ្ចេញ ឬការគម្រាមកំហែងពីអាវុធនុយក្លេអ៊ែរ ឬសារជាតុគីមី ឬជីវ ដែលរួមមានតែមិនកម្រិតត្រឹមចំណាយដែលបង្កដោយ ឬបង្កឲ្យមានដោយសកម្មភាពភេរវកម្ម ឬសង្គ្រាម ដោយមិនគិតពីហេតុបង្កណាមួយ ឬ
(xxi) ចំណាយណាមួយដែលបង្កឡើងពីមូលហេតុផ្សេងៗ ក្រៅពីការរងរបួសបង្កដោយគ្រោះថ្នាក់ចៃដន្យ ប្រសិនបើមិនបានជ្រើសរើសជម្រើសពេញលេញនៅក្នុងវិញ្ញាបនបត្រធានារ៉ាប់រង និងបញ្ជីសមាជិក។

## 6. ករណីមិនធានាពាក់ព័ន្ធនឹងទណ្ឌកម្មអន្តរជាតិ

(i) ក្រុមហ៊ុនអាចបញ្ចប់បណ្ណសន្យារ៉ាប់រងនេះនៅពេលណាមួយក៏បាន (ដោយបញ្ចប់សុពលភាពគិតចាប់ពីកាលបរិច្ឆេទចេញបណ្ណសន្យារ៉ាប់រង ឬផ្សេងពីនេះ)តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់បណ្ណសន្យារ៉ាប់រង ក្នុងករណីដែលម្ចាស់បណ្ណសន្យារ៉ាប់រង ឬបុគ្គល ឬអង្គភាពណាមួយដែលពាក់ព័ន្ធនៅក្នុងបណ្ណសន្យារ៉ាប់រងនេះ តាមការយល់ឃើញរបស់ក្រុមហ៊ុន ត្រូវបានរកឃើញថាបានបង្ក ឬអាចនឹងបង្កហានិភ័យផ្នែកទណ្ឌកម្ម ការហាមប្រាម ឬការរឹតបន្តឹងមកដល់ក្រុមហ៊ុនតាមរយៈសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ឬការដាក់ទណ្ឌកម្មផ្នែកសេដ្ឋកិច្ច/ពាណិជ្ជកម្ម លិខិតបទដ្ឋានគតិយុត្តិរបស់សហភាពអឺរ៉ុប ចក្រភពអង់គ្លេស ឬសហរដ្ឋអាមេរិក ឬតាមការអនុវត្តច្បាប់ ឬបទប្បញ្ញត្តិផ្សេងៗស្តីពីការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ឬពាណិជ្ជកម្ម។ ក្រុមហ៊ុននឹងមិនធ្វើប្រតិបត្តិការអាជីវកម្មជាមួយម្ចាស់បណ្ណសន្យារ៉ាប់រងពាក់ព័ន្ធនឹងបណ្ណសន្យារ៉ាប់រងនេះនោះទេ ដោយរួមបញ្ចូលទាំង និងមិនកំណត់ត្រឹមតែការផ្តល់ ឬទទួលទូទាត់ទឹកប្រាក់ក្រោមបណ្ណសន្យារ៉ាប់រងនេះ។

(ii) ដោយមិនមានការប៉ះពាល់ដល់សុពលភាពកថាខណ្ឌ (i) ខាងលើនៃប្រការនេះទេ បណ្ណសន្យារ៉ាប់រងនេះនឹងត្រូវចាត់ទុកថា មិនត្រូវផ្តល់ការធានាណាមួយឡើយ ហើយក្រុមហ៊ុនក៏មិនទទួលខុសត្រូវក្នុងការទូទាត់សំណង ឬផ្តល់អត្ថប្រយោជន៍ផ្សេងៗ ក្នុងទំហំដែលការផ្តល់ការការពារ ការទូទាត់សំណង ឬការផ្តល់ជូននូវអត្ថប្រយោជន៍ផ្សេងៗទាំងនោះ អាចនាំឲ្យក្រុមហ៊ុនប្រឈមមុខនឹងហានិភ័យនានាពាក់ព័ន្ធនឹងការដាក់ទណ្ឌកម្ម ការហាមប្រាម ឬការរឹតបន្តឹងក្រោមសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ឬការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ឬពាណិជ្ជកម្ម លិខិតបទដ្ឋានគតិយុត្តិរបស់សហភាពអឺរ៉ុប ឬចក្រភពអង់គ្លេស ឬសហរដ្ឋអាមេរិក ឬការអនុវត្តច្បាប់ ឬបទប្បញ្ញត្តិផ្សេងៗស្តីពីការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ឬពាណិជ្ជកម្ម។

(iii) ជាកាតព្វកិច្ចដែលត្រូវអនុវត្តបន្តជាប្រចាំ ម្ចាស់បណ្ណសន្យារ៉ាប់រងត្រូវជូនដំណឹងជាបន្ទាន់ទៅកាន់ក្រុមហ៊ុន ប្រសិនបើមានករណីផ្លាស់ប្តូរអត្តសញ្ញាណ ស្ថានភាព (មុខដំណែង) លក្ខន្តិកៈ (ក្នុងករណីជាក្រុមហ៊ុន) ក្រុមហ៊ុនពាក់ព័ន្ធនឹងម្ចាស់បណ្ណសន្យារ៉ាប់រងក្រោមខ្លឹមសារនៃបណ្ណសន្យារ៉ាប់រងនេះ ព័ត៌មានលម្អិត និងឯកសារអត្តសញ្ញាណកម្មរបស់ម្ចាស់បណ្ណសន្យារ៉ាប់រង ឬបុគ្គល ឬអង្គភាពនានាដែលពាក់ព័ន្ធនឹងបណ្ណសន្យារ៉ាប់រងនេះ។

សុខភាព និងជីវិត
កាន់តែប្រសើរ

# AIA COMCARE

ប្រសិនបើអ្នកមានសំណួរ  និងចង់ដឹងថាសេវាកម្មរបស់ AIA COMCARE អាចជួយអ្នកបានកម្រិតណា សូមទំនាក់ទំនងមកកាន់ ទីប្រឹក្សាផែនការជីវិតរបស់ អេ អាយ អេ ឬ ផ្នែកសេវាកម្មអតិថិជន 086 999 242។


**ការិយាល័យកណ្ដាល**

អគារ ជីអាយអេ ថៅអឺរ ជាន់ទី31 ផ្លូវសុភមង្គល ភូមិ14 សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**សាខាភ្នំពេញ**

ជាន់ទី 8 និងទី 9 អគារ CITY TOWER
លេខ 321 មហាវិថីម៉ៅសេទុង សង្កាត់ផ្សារដេប៉ូ 1 ខណ្ឌទួលគោក រាជធានីភ្នំពេញ

**សាខាសៀមរាប**

អគារលេខ 29 និង 30
ផ្លូវហ្សាលដឺហ្គោល សាលាកន្សែង សង្កាត់ស្វាយដង្គំ ទីរួមខេត្តសៀមរាប

**សាខាបាត់ដំបង**

ផ្ទះលេខ 2-6ផ្លូវលេខ 3 ភូមិកម្មករ សង្កាត់ស្វាយប៉ោ
ក្រុងបាត់ដំបង ខេត្តបាត់ដំបង

**សាខាកំពង់ចាម**

ភូមិ 15 សង្កាត់កំពង់ចាម ខណ្ឌកំពង់ចាម ខេត្តកំពង់ចាម

**សាខាកំពត**

ផ្លូវលេខ 700 ភូមិ 1ឧសភា សង្កាត់កំពង់កណ្ដាល ក្រុងកំពត
ខេត្តកំពត

086 999 242 | AIA.COM.KH | AIA CAMBODIA